ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង កិច្ចការនារី

លេខ ......១២០...... កកន/ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតការិយាល័យចំណុះនាយកដ្ឋាន ក្រោមឱវាទក្រសួងកិច្ចការនារី

## រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងតាមសំណូមពរការងារចាំបាច់ ។

## សំរេច

**ប្រការ ១** :ត្រូវបានបង្កើតការិយាល័យចំណុះនាយកដ្ឋាននានា ក្រោមឱវាទក្រសួងកិច្ចការនារីដូចមានខាងក្រោម :

ក. **អគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ**

១. **នាយកដ្ឋានរដ្ឋបាល-បុគ្គលិក មាន ០៥ ការិយាល័យ :**

- ការិយាល័យរបៀប
- ការិយាល័យបុគ្គលិក
- ការិយាល័យពិធីការ

- ការិយាល័យបូកសរុប
- ការិយាល័យបៀវត្ស -ពលកម្ម

**២. នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ មាន ០៥ ការិយាល័យ :**

- ការិយាល័យគ្រប់គ្រងថវិកា
- ការិយាល័យគណនេយ្យ
- ការិយាល័យបេឡា
- ការិយាល័យសំភារៈ និងផ្គត់ផ្គង់
- ការិយាល័យគ្រប់គ្រងមូលនិធិអន្តរជាតិ

**៣. នាយកដ្ឋានផែនការ និងស្ថិតិ មាន ០៤ ការិយាល័យ :**

- ការិយាល័យផែនការ និងរបាយការណ៍
- ការិយាល័យតាមដានគំរោង
- ការិយាល័យស្ថិតិ
- មជ្ឈមណ្ឌលព័ត៌មានស្ត្រី ( ថ្នាក់ស្មើការិយាល័យ )

**ខ. អគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍន៍សេដ្ឋកិច្ច**

**១ . នាយកដ្ឋានព័ត៌មាន មាន ០៤ ការិយាល័យ :**

- ការិយាល័យស្រាវជ្រាវ និងផលិតព័ត៌មាន
- ការិយាល័យផ្សព្វផ្សាយតាមវិទ្យុ
- ការិយាល័យផ្សព្វផ្សាយតាមទូរទស្សន៍
- ការិយាល័យបោះពុម្ពផ្សាយ

**២ . នាយកដ្ឋានសមភាពយេនឌ័រ មាន ០៤ ការិយាល័យ :**

- ការិយាល័យគោលនយោបាយ
- ការិយាល័យរបាយការណ៍ជាតិ
- ការិយាល័យអភិបាលកិច្ចមូលដ្ឋាន
- ការិយាល័យស្ត្រីក្នុងតួនាទីធ្វើសេចក្តីសំរេច

**៣ . នាយកដ្ឋានអភិវឌ្ឍសេដ្ឋកិច្ច មាន ០៤ ការិយាល័យ :**

- ការិយាល័យឥណទាន
- ការិយាល័យពង្រីកឱកាសការងារស្ត្រី
- ការិយាល័យកែច្នៃផលិតផល
- ការិយាល័យអភិវឌ្ឍជំនួញខ្នាតតូច-មធ្យម ១៩៥០៧

**ឥ. អគ្គនាយកដ្ឋានអភិវឌ្ឍសង្គម**

**១ . នាយកដ្ឋានការពារផ្លូវច្បាប់ មាន ០៤ ការិយាល័យ :**

- ការិយាល័យផ្នែកច្បាប់
- ការិយាល័យទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ
- ការិយាល័យទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ
- ការិយាល័យទប់ស្កាត់ការរំលោភផ្លូវភេទ

**២ . នាយកដ្ឋានស្ត្រី និងសុខភាព មាន ០៤ ការិយាល័យ :**

- ការិយាល័យលើកកម្ពស់សុខភាពបន្តពូជ
- ការិយាល័យលើកកម្ពស់អាហារូបត្ថម្ភ
- ការិយាល័យបង្ការជំងឺអេដស៍
- ការិយាល័យបង្ការជំងឺផ្សេងៗ

**៣ . នាយកដ្ឋានស្ត្រី និងការអប់រំ មាន ០៤ ការិយាល័យ :**

- ការិយាល័យគ្រប់គ្រងអន្តេវាសិកដ្ឋានសិស្សស្រី
- ការិយាល័យលើកកម្ពស់ការអប់រំស្ត្រី និងកុមារី
- ការិយាល័យអប់រំបំនិនជីវិត
- ការិយាល័យអប់រំកុមារតូច

**ប្រការ ២ :** តួនាទី ភារកិច្ចជាក់ស្តែងរបស់ការិយាល័យនីមួយៗ អាស្រ័យដោយនាយកដ្ឋានសាមីរៀបចំឡើង និងលើក សំណើជូនរដ្ឋមន្ត្រីពិនិត្យ សំរេច ក្រោយពីបានការឯកភាពពីអគ្គនាយកដ្ឋានរបស់ខ្លួន ។

**ប្រការ ៣ :** ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ០១រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានន័យផ្ទុយនិងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានក្រោមឱវាទក្រសួងត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ១៧៤៧

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥

រដ្ឋមន្ត្រី

ឃឹម_ចំរើន

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដូចប្រការ ៥
- ឯកសារ -កាលប្បវត្តិ